**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៤១អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល មាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា ២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំង៖

១-លោក **សន ពៅ** ជាអនុប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន។

២-លោក **ស៊ុំ ឈុំឡុង** ជាអនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន។

៣-លោក **ហាក់ ធីរោ** ជាអនុប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង**។

៤-លោក **ឆេង វណ្ណារិទ្ធ** ជាអនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង**។

**មាត្រា២:** ត្រូវបានប្រគល់ភារកិច្ចជូន៖

១-លោកស្រី **សៀង ហ៊ុយ** ឲ្យបំពេញមុខងារជាអនុប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **អគ្គនាយករង**។

២-លោក **លាង សុភាព** ឲ្យបំពេញមុខងារជាលេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

៣-លោក **ឃិន យ៉េង** ឲ្យបំពេញមុខងារជាលេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ**ប្រធាននាយកដ្ឋាន**។

៤-លោក **ឈឹម សុខាន់ដារា** ឲ្យបំពេញមុខងារជាលេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ**ប្រធាននាយកដ្ឋាន**។

៥-លោក **យង់ ពៅ** ឲ្យបំពេញមុខងារជាលេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

៦-លោក **ទី សុខគង់** ឲ្យបំពេញមុខងារជាប្រធានផ្នែកភាសានិងភាសាវិទ្យានៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

៧-លោក **មាឃ បូរ៉ា** ឲ្យបំពេញមុខងារជាប្រធានផ្នែកសិលាចារឹកវិទ្យា នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

៨-លោក **ណុន សុខា** ឲ្យបំពេញមុខងារជាប្រធានផ្នែកអក្សរសាស្ត្រនិងអក្សរសិល្ប៍នៃវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

៩-លោក **នូ ឌីឡា** ឲ្យបំពេញមុខងារជាប្រធានផ្នែកព័ត៌មានវិទ្យានិងទូរគមនាគមន៍នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១០-លោក **ហាក់ សុខេង** ឲ្យបំពេញមុខងារជាប្រធានផ្នែកគណិតវិទ្យានិងស្ថិតិនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជាមានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១១-លោក **នង ភាឌីណាល់** ឲ្យបំពេញមុខងារជាប្រធានផ្នែករូបវិទ្យា និងថាមពល នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១២-លោកស្រី **ចេក សុថា** ឲ្យបំពេញមុខងារជាប្រធានផ្នែកគីមីនិងចំណីអាហារនៃវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជាមានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៣-លោក **មាឃ សារី** ឲ្យបំពេញមុខងារជាប្រធានផ្នែកវិទ្យាសាស្ត្រអប់រំ នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៤-លោក **ឈឿន សាខន** ឲ្យបំពេញមុខងារជាប្រធានផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៥-លោក **ផុន កសិកា** ឲ្យបំពេញមុខងារជាប្រធានផ្នែកបុរាណវិទ្យានៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៦-លោក **សួន សុភា** ឲ្យបំពេញមុខងារជាប្រធានផ្នែកកសិកម្ម រុក្ខាប្រមាញ់និងនេសាទនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្មនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៧-លោក **ហុខ វណ្ណៈ** ឲ្យបំពេញមុខងារជាប្រធានផ្នែកទំនាក់ទំនងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

១៨-លោក **សូ ម៉េន** ឲ្យបំពេញមុខងារជាប្រធានផ្នែកទំនាក់ទំនងសង្គមកិច្ចនិងសុខាភិបាលនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៤២.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យ ១១៦ អនក្រ.គត ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

-បានឃើញអនុក្រឹត្យលេខ ៧០០ អនក្រ.គត ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានអនុញ្ញាតឱ្យលោក **ម៉ែន ថារ័ត្ន** ប្រធានផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស នៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល ០២ ឆ្នាំ លើកទី២ គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៤៣.អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំនួន០២គ្រឿង ជូនសប្បុរសជន ចំនួន០២រូប ដែលបានជួយសាងសង់មណ្ឌលសុខភាពអូររាំង ខេត្តមណ្ឌលគីរី រួចរាល់ជាស្ថាពរ ដោយចំណាយថវិកាសរុបចំនួន ៤៤.១៨៥ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

-លោក ជោ គឹមហេង ប្រធានអង្គការសន្តិភាពអាល្លឺម៉ង់ (PEACE)

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:**

-លោក គុជ វណ្ណា អនុប្រធានមន្ទីរសុខាភិបាល ខេត្តមណ្ឌលគិរី

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០៤៤ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ជូនទីប្រឹក្សាចិន នៅវិទ្យាស្ថានទ័ពជើងគោក ចំនួន ០៦ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ត្រូវបានបញ្ចប់បេសកកម្ម ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ១-វរសេនីយ៍ឯកពិសេស | **អ៊ូ សៀក អ៊ូ** | Senior Colonel Wu Xue Wu សមាជិក នាយមុខវិជ្ជាអេឡិចត្រូនិច |
| ២-វរសេនីយ៍ឯកពិសេស | **សុខឆាខ ស៊ុន** | Senior Colonel Song Chang Shun សមាជិក សាស្ត្រាចារ្យផ្នែកគ្រប់គ្រង |
| ៣-វរសេនីយ៍ឯកពិសេស | **ឈីវ ឆាវ ហ្វាន** | Senior Colonel Qiu Chao Fan សមាជិកនាយមុខវិជ្ជាកាំភ្លើងធំ និងកាំជ្រួច |
| ៤-វរសេនីយ៍ទោ | **ហ៊ូ យុខ** | Lieutenant Colonel Hu Yong សមាជិក គ្រូភាសាចិន |
| ៥-វរសេនីយ៍ទោ | **លី ជួន** | Lieutenant Colonel Li Jun សមាជិក វិស្វករត្រួតពិនិត្យសំណង់ |

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា**

-វរសេនីយ៍ត្រី **លី ចាង** Major Li Jiang បកប្រែ ភាសាខ្មែរ

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/ HR

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០៤៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ២០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅឃុំព្រៃរំដេង ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | ឌូច គីម | ប្រធានក្រុមហ៊ុន Kim Mex Construction | ថវិកា ១២.០០០ ដុល្លារ |
| ២- | លោក | មាន រ៉ាំធុធ | ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.៥០០ ដុល្លារ |
| ៣- | លោក | អ៊ុំ ចន្ណា | អគ្គនាយករងបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.២០០ ដុល្លារ |
| ៤- | លោក | គីម ស៊ាន | ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.០០០ ដុល្លារ |
| ៥- | លោក | ចាន់ សុចន្ណារ៉ា | ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.០០០ ដុល្លារ |
| ៦- | លោក | សួរ សុផល | ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.០០០ ដុល្លារ |
| ៧- | លោក | សែម សាធឿន | អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.០០០ ដុល្លារ |
| ៨- | លោក | ប៊ូ ណារិន | អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១១.០០០ ដុល្លារ |
| ៩- | លោក | ម៉ែន សុខុម | មន្ត្រី នា.ផ្គត់ផ្គង់ ហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១០.៥០០ ដុល្លារ |
| ១០- | លោក | មាស ផាន់ណា | អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ | ថវិកា ១០.៤០០ ដុល្លារ |
| ១១- | លោក | ខន កែវមនោ | មន្ត្រី នា.បទបញ្ញាតិ ត្រួតពិនិត្យ នៃអាជ្ញាធរមីនកម្ពុជា | ថវិកា ១០.២០០ ដុល្លារ |
| ១២- | លោក | ម៉េង សារុន | មេឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៣- | លោក | ខែ ប្រុស | ជំទប់ទី១ ឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៤- | លោក | ខែ សាធឿន | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៥- | លោក | អុក យ៉ាក់ | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៦- | លោក | លី ចន្ណះ | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |

| | | | | | |
|---|---|---|---|---|---|
| ១៧- | លោក | អ៊ី | សឿ | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៨- | លោក | មួង | ហាង | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ១៩- | លោក | ចៅ | ម៉ែនអូន | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |
| ២០- | លោក | ស៊ុំ | ឆាន | ក្រុមប្រឹក្សាឃុំព្រៃរំដេង | ថវិកា ១០.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៤៦ .អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ១៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅឃុំព្រៃរំដេង ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ឡោ សុជាតិ** | សកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង |
| ២- | លោក | **សាម សាយ** | ប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣- | លោក | **ស៊ុម សាន** | ជំនួយការ ឯ.ឧ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤- | លោក | **មាស មុនថុន** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៥- | លោក | **ស៊ិន ម៉ាត** | ប្រធានក្រុមហ៊ុន ស៊ិន វ៉ាត Construction |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ**

| | | | |
|---|---|---|---|
| ១- | លោក | **នៃ គីមឈាង** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ |
| ២- | លោក | **អ៊ុំ ចាន់ណា** | អនុប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៣- | លោក | **កែម ផល្លា** | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ៤- | លោក | **ចាន់ វឌ្ឍា** | ប្រធាននាយកដ្ឋានអាជ្ញាធរមីន |
| ៥- | លោក | **ឯក សុខីណា** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៦- | លោក | **នួន សុខា** | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ |
| ៧- | លោក | **ជា ទិសេស** | ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ |

៨- លោក **ឈី ឡាយ** ជំនួយការផ្ទាល់ ឯ.ឧ សុខ ផល អគ្គស្នងការនគរបាលជាតិ

៩- លោក **ចាន់ សុខវណ្ណឌី** ប្រធានការិយាល័យ ក្រសួងអភិវឌ្ឍន៍ជនបទ

១០- លោក **ម៉ម តាម៉ាល់** ប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥១ .សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវ អំពីវប្បធម៌ជនជាតិគួយនៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវអំពីវប្បធម៌ជនជាតិគួយនៅកម្ពុជាដែលមានសមាសភាពដូចខាងក្រោម៖

**ក-គណៈកម្មការទទួលខុសត្រូវរួម**

| | | |
|---|---|---|
| ១-ឯកឧត្តម **ជុច ភឿន** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង** | ទីប្រឹក្សារាជរដ្ឋាភិបាល | អនុប្រធាន |

| | | |
|---|---|---|
| ៣-លោកជំទាវ **តាន់ ធានី** | អគ្គលេខាធិការគណៈកម្មការជាតិយូណេស្កូកម្ពុជា | សមាជិក |
| ៤-ឯកឧត្តម **សួស យ៉ារ៉ា** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម **ហាប់ ទូច** | អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |

**ខ-គណៈកម្មការប្រតិបត្តិគម្រោង**

| | | |
|---|---|---|
| ១-បណ្ឌិត **ធុយ ចាន់ធួន** | អនុប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា | ប្រធាន |
| ២-លោក **ហេង សុផាឌី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣- លោក **ផាន់ ណាឌី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៤-លោក **ផេង ស៊ីថា** | ព្រឹទ្ធបុរសមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | សមាជិក |
| ៥-Mr. **Phillipe Delangh** | ប្រធានផ្នែកទទួលបន្ទុកខាងវប្បធម៌ នៃអង្គការយូណេស្កូ ភ្នំពេញ | សមាជិក |
| ៦-Mr. **Blaise Kilian** | មន្ត្រីសម្របសម្រួលនិងសហការកម្មវិធីMDG នៃអង្គការយូណេស្កូ ភ្នំពេញ | សមាជិក |
| ៧-លោកស្រី **សំ ធីតា** | អនុប្រធាននាយកដ្ឋានសារៈមន្ទីរ | សមាជិក |
| ៨-លោក **ខៀវ ច័ន្ទ** | មន្ត្រីផ្នែកបុរាណវិទ្យា នៃនាយកដ្ឋានរៀបចំដែនដី និង គ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរអប្សរា | សមាជិក |
| ៩-លោក **ជុំ គិរស្មី** | មន្ត្រីនាយកដ្ឋានរមណីយដ្ឋាននិងបុរាណវិទ្យា នៃអាជ្ញាធរព្រះវិហារ | សមាជិក |
| ១០-លោក **ឈឹម សុខាន់ដារា** | មន្ត្រីស្រាវជ្រាវផ្នែកបុរាណវិទ្យា នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១១-លោក **ផុន កសិកា** | មន្ត្រីស្រាវជ្រាវផ្នែកបុរាណវិទ្យា វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១២-លោក **លឹម សុក្រាត** | មន្ត្រីស្រាវជ្រាវផ្នែកបុរាណវិទ្យានៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ១៣-លោក **អាត ឡៅ** | មន្ត្រីស្រាវជ្រាវផ្នែកប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងស្រាវជ្រាវអំពីវប្បធម៌ជនជាតិគួយនៅកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ដើម្បីអភិរក្សនិងអភិវឌ្ឍន៍មរតកវប្បធម៌ឡស្លដែកបុរាណរបស់ជនជាតិគួយ

- សិក្សាស្រាវជ្រាវចងក្រងនិងផ្សព្វផ្សាយឯកសារអំពីវប្បធម៌ឡូស្លូដែកបុរាណរបស់ជនជាតិគួយ
- សិក្សាកំណត់ទីតាំង តំបន់ និងអាយុកាល ដើម្បីអភិរក្សនិងអភិវឌ្ឍវប្បធម៌ជនជាតិគួយ
- ប្រមូលលទ្ធផលសិក្សាស្រាវជ្រាវតម្កល់ទុកក្នុងសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ
- សម្របសម្រួលជាមួយក្រសួងនិងស្ថាប័ន ដែលមានសមត្ថកិច្ចស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍ ពាក់ព័ន្ធ នឹងប្រធានបទខាងលើ និងទទួលភារកិច្ចមួយចំនួនទៀត តាមការប្រគល់ជូនពីរាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ៣.-**

គណៈកម្មការនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ និងបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។

**ប្រការ៤.-**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់អាជ្ញាធរជាតិព្រះវិហារ សម្រាប់ដំណើរការការងារ។

**ប្រការ ៥.-**

សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៦.-**

ថវិកាចំណាយសម្រាប់ដំណើរការបានមកពីថវិកាពិសេសរបស់រដ្ឋាភិបាល និងបានមកពីប្រភពផ្សេងៗ។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានអាជ្ញាធរជាតិព្រះវិហារ ប្រធានអាជ្ញាធរអប្សរា ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៙៙៙✵៚៚៚

ស្ថាប័នប្រឆាំងអំពើពុករលួយ
ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
លេខ......០០៧/១១ ប្រក.....ក.ជ.ប.ព.

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអង្គភាពប្រឆាំងអំពើពុករលួយ

---

## ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- យោងតាមការស្នើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ កំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអង្គភាពប្រឆាំងអំពើពុករលួយ ។

## ជំពូកទី២
## រចនាសម្ព័ន្ធ បេសកកម្ម និងភារកិច្ច

**ប្រការ ២.-**

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនដែលមានបេសកកម្ម និងភារកិច្ចដូចក្នុងប្រកាសនេះ ។
ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១(មួយ)រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។
រចនាសម្ព័ន្ធការិយាល័យចំណុះឲ្យនាយកដ្ឋាននីមួយៗ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

## ជំពូកទី៣
## ការិយាល័យចំណុះនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**ប្រការ ៣.-**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន៤ ដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យលទ្ធកម្ម
- ការិយាល័យបណ្ណាល័យ និងប្រវត្តិ ។

**ប្រការ ៤.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- កសាងផែនការលើការគ្រប់គ្រងកិច្ចការរដ្ឋបាល និងលើកគម្រោងតម្រូវការបុព្វហេតុរដ្ឋបាលទូទៅ
- រៀបចំទីកន្លែងទទួលពាក្យប្តឹង និងប្រអប់សំបុត្រសរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់គ្រងឯកសារ និងលិខិតរដ្ឋបាលចេញ ចូល ដែលមិនមែនពាក្យប្តឹង
- សម្របសម្រួលសកម្មភាពគ្រប់គ្រងផ្នែករដ្ឋបាលរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់គ្រង និងធ្វើចរាចរណ៍ឯកសាររដ្ឋបាលរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និបាត សន្និសីទសារព័ត៌មាន និងពិធីផ្សេងៗ
- រៀបចំលិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើរជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
- រៀបចំចតចម្លង ផ្សព្វផ្សាយលិខិតផ្សេងៗ ជូនថ្នាក់ដឹកនាំ និងនាយកដ្ឋានពាក់ព័ន្ធ
- គ្រប់គ្រងសេវាទទួល និងផ្តល់ពត៌មានជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងសាធារណជន
- ទំនាក់ទំនងជាមួយបណ្តាញផ្សព្វផ្សាយ និងសារពត៌មាននានា ដើម្បីផ្សព្វផ្សាយព័ត៌មានផ្សេងៗ ជូនសាធារណជន
- ទទួលរៀបចំការងារពិធីការសម្រាប់ថ្នាក់ដឹកនាំ និងពិធីការទូទៅ
- ធ្វើរបាយការណ៍ និងកំណត់ហេតុប្រជុំរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ របស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងទិសដៅរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រចាំឆមាស និងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ៥.-**

ការិយាល័យហិរញ្ញវត្ថុ មានភារកិច្ច ៖

- រៀបចំគម្រោងថវិកា និងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- គ្រប់គ្រងថវិកា និងហិរញ្ញវត្ថុសម្រាប់ដំណើរការការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- គ្រប់គ្រង និងធ្វើបញ្ជីសារពើភណ្ឌលើទ្រព្យសម្បត្តិរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ទទួល និងបែងចែកសម្ភារៈបរិក្ខាជូនស្ថាប័នប្រឆាំងអំពើពុករលួយ
- ផ្តល់សេវារដ្ឋបាលជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- គ្រប់គ្រង និងបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ប្រចាំខែជូនមន្ត្រីរាជការ កម្លាំងសន្តិសុខ បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ស្នើសុំថវិកាអប្បហារដែលបានពីបទល្មើសពុករលួយ
- ទទួល និងពិនិត្យនូវសំណើថវិកា
- គ្រប់គ្រងបណ្តាញទូរស័ព្ទ ទូរសារ ខ្សែកាប អ៊ិនធើណេត និងចាត់ចែងរាល់មធ្យោបាយធ្វើដំណើរផ្សេងៗ
- លើកគម្រោងផែនការសេដ្ឋកិច្ច សង្គមកិច្ច និងវិនិយោគសាធារណៈ របស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- គ្រប់គ្រងបញ្ជីគណនេយ្យ និងការងារគណនេយ្យ
- គ្រប់គ្រងថវិការជូទេយ្យបុរេប្រទាន
- គ្រប់គ្រងបេឡាទូទៅ បេឡាសម្រាប់បៀវត្សមន្ត្រីរាជការ កម្លាំងសន្តិសុខ បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ប្រមូលថវិកាបេឡាសន្តិសុខសង្គមរបស់មន្ត្រីរាជការ និងបើកប្រាក់សង្គ្រោះសង្គមជូនមន្ត្រីរាជការ កម្លាំងសន្តិសុខ បុគ្គលិកកិច្ចសន្យា និងបុគ្គលិកអណ្តែត
- ត្រួតពិនិត្យលើការគ្រប់គ្រងបេឡាជាប្រចាំ
- លើកគម្រោង និងធ្វើផែនការផ្គត់ផ្គង់ ឧបករណ៍សម្ភារៈបរិក្ខារ និងការជួសជុលអគារ ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការសាងសង់ប្រចាំឆ្នាំ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ៦.-**

ការិយាល័យលទ្ធកម្ម មានភារកិច្ច ៖

- ប្រតិបត្តិកិច្ចការលទ្ធកម្មសាធារណៈរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- រៀបចំបែបបទ និងចាត់ចែងសម្រាប់ដំណើរការនីតិវិធី នៃការធ្វើលទ្ធកម្ម
- ត្រួតពិនិត្យបច្ចេកទេស នៃដំណើរការលទ្ធកម្មសាធារណៈ
- ពិនិត្យស្រាវជ្រាវតម្លៃ និងរៀបចំកិច្ចការដេញថ្លៃ
- គ្រប់គ្រងបន្ទុកគណនី នៃការអនុវត្តលទ្ធកម្មសាធារណៈ
- ធ្វើគម្រោងការងារលទ្ធកម្ម និងសកម្មភាពការងារផ្សេងៗទៀត
- ត្រួតពិនិត្យ និងធ្វើផែនការលទ្ធកម្មផ្គត់ផ្គង់ឧបករណ៍ សម្ភារៈបរិក្ខាផ្សេងៗ និងប្រេងឥន្ធនៈសម្រាប់ការប្រើប្រាស់ក្នុងស្ថាប័នប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ៧.-**

ការិយាល័យបណ្ណាល័យ និងប្រវត្តិ មានភារកិច្ច ៖

- សហការជាមួយគ្រប់នាយកដ្ឋាន ដើម្បីរៀបចំរូបថត រូបវីដេអូ អត្ថបទ ព័ត៌មាននានា បម្រើឱ្យគេហទំព័ររបស់អង្គភាព
- រៀបចំ និងគ្រប់គ្រងកិច្ចការបណ្ណាល័យ ឯកសារបណ្ណសារ សម្រាប់ការសិក្សាស្រាវជ្រាវ
- គ្រប់គ្រងសារមន្ទីរ និងរៀបចំតាំងពិព័រណ៍រូបភាព ឯកសារ និងឧបករណ៍សម្ភារៈ ដែលអង្គភាពប្រើប្រាស់ក្នុងការប្រឆាំងអំពើពុករលួយជូនសាធារណជន
- សិក្សា ស្រាវជ្រាវឯកសារ ជាភាសាជាតិ និងភាសាបរទេស ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ

- សម្របសម្រួលបកប្រែឯកសារពីភាសាបរទេស មកជាភាសាជាតិ និងភាសាជាតិទៅភាសាបរទេស តាមការចាំបាច់
- ប្រមូល រៀបចំគ្រប់គ្រងឯកសារដែលធ្វើការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស
- ចងក្រងឯកសារ សកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដោយរូបភាព និងវីដេអូ
- គ្រប់គ្រង និងរក្សាលិខិតបទដ្ឋានគតិយុត្តិនានា
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

## ជំពូកទី៤
## ការិយាល័យចំណុះនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល

**ប្រការ ៨.-**

នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល មានការិយាល័យចំណុះចំនួន៣ ដូចខាងក្រោម ៖

- ការិយាល័យបុគ្គលិក
- ការិយាល័យបណ្តុះបណ្តាល
- ការិយាល័យសុខភាព និងកីឡា ។

**ប្រការ ៩.-**

ការិយាល័យបុគ្គលិក មានភារកិច្ច ៖

- គ្រប់គ្រងបុគ្គលិកទាំងអស់របស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- រៀបចំបែបបទជ្រើសរើសមន្ត្រី តែងតាំង ផ្លាស់ប្តូរ ដំឡើងឋានៈ ដាក់វិន័យ និងដាក់ឱ្យចូលនិវត្តន៍ តាមច្បាប់កំណត់
- រៀបចំកម្មប្រាក់បៀវត្សមន្ត្រីរាជការ
- រៀបចំបែបបទ និងលើកសំណើដើម្បីផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំមន្ត្រីរាជការរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ និងអ្នកដែលមានស្នាដៃការងារល្អ ជូនអង្គភាពប្រឆាំងអំពើពុករលួយ
- រៀបចំផែនការ និងកំណត់ក្របខណ្ឌ និងចំនួនបុគ្គលិករបស់អង្គភាពប្រឆាំងអំពើពុករលួយ ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត
- ធ្វើទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារបុគ្គលិក
- រៀបចំកសាងសេចក្តីព្រាងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធកិច្ចការមន្ត្រីរាជការ កម្លាំងសន្តិសុខ បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- រៀបចំរាល់សំណុំលិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព
- រៀបចំគំរូបែបបទលិខិតអនុញ្ញាតច្បាប់ឈប់សម្រាក និងសម្របសម្រួលការងារសុំច្បាប់ឈប់សម្រាក
- រៀបចំ ចាត់ចែងមន្ត្រីរាជការ ចូលរួមក្នុងសកម្មភាព នៃពិធីបុណ្យជាតិ អន្តរជាតិ មិទ្ទីង ព្យុហយាត្រា និងសកម្មភាពសង្គមផ្សេងៗ
- រៀបចំធ្វើប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ កម្លាំងសន្តិសុខ និងបុគ្គលិកផ្សេងទៀត
- រៀបចំវាយតម្លៃការតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- រៀបចំបៀវត្សមន្ត្រីរាជការ កម្លាំងសន្តិសុខទៅតាមក្របខ័ណ្ឌ និងរចនាសម្ព័ន្ធ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១០.-**

ការិយាល័យបណ្តុះបណ្តាល មានភារកិច្ច ៖

- រៀបចំផែនការបណ្តុះបណ្តាល និងហ្វឹកហ្វាត់ដល់មន្ត្រីរាជការ និងបុគ្គលិកអង្គភាពប្រឆាំងអំពើពុករលួយ
- បណ្តុះបណ្តាល ហ្វឹកហាត់ធនធានមនុស្ស និងពង្រឹងសមត្ថភាពវិជ្ជាជីវៈប្រឆាំងអំពើពុករលួយទាំងក្នុង និងក្រៅប្រទេស
- រៀបចំកម្មវិធី និងឯកសារសម្រាប់បង្រៀន និងហ្វឹកហាត់មន្ត្រីរបស់អង្គភាព និងត្រួតពិនិត្យការហ្វឹកហាត់
- រៀបចំការបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ពង្រឹងសមត្ថភាពមន្ត្រីរាជការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអង្គការអន្តរជាតិនានា ក្នុងការបណ្តុះបណ្តាល បំពាក់បំប៉នដល់មន្ត្រីរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- សហការជាមួយការិយាល័យពាក់ព័ន្ធ លើការចាត់តាំងមន្ត្រីរាជការចូលរួមក្នុងកិច្ចប្រជុំ កម្មវិធីសិក្ខាសាលា ទស្សនកិច្ចសិក្សា និងការសិក្សារយៈពេលខ្លី មធ្យម និងវែង ក្នុង និងក្រៅប្រទេស
- សម្របសម្រួល និងរៀបចំទស្សនកិច្ចសិក្សា ការធ្វើកម្មសិក្សារបស់មន្ត្រី និងនិស្សិត ក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១១.-**

ការិយាល័យសុខភាព និងកីឡា មានភារកិច្ច ៖

- ផ្តល់ការប្រឹក្សា និងពិគ្រោះយោបល់ស្តីពីបញ្ហាសុខភាពជូនមន្ត្រីក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- រៀបចំលិខិតបទដ្ឋានផ្សេងៗ ទាក់ទងសុខភាព និងកីឡា
- ពិនិត្យសុខភាពជនល្មើស
- រៀបចំគោលនយោបាយឧបត្ថម្ភការកិច្ចប៉ះពាល់សុខភាពជូនមន្ត្រីរាជការ ក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- រៀបចំ និងគ្រប់គ្រងទីលាន សម្ភារៈកីឡានានា ដែលពាក់ព័ន្ធនឹងសុខភាព និងកីឡា នៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

## ជំពូកទី៥
## ការិយាល័យចំណុះនាយកដ្ឋានសន្តិសុខ

**ប្រការ ១២.-**

នាយកដ្ឋានសន្តិសុខ មានការិយាល័យចំណុះចំនួន៤ ដូចខាងក្រោម ៖

- ការិយាល័យសន្តិសុខ
- ការិយាល័យអនុរក្ស
- ការិយាល័យអន្តរាគមន៍ និងការពារសាក្សី
- ការិយាល័យសុវត្ថិភាព និងគ្រប់គ្រងអាវុធ ។

**ប្រការ ១៣.-**

ការិយាល័យសន្តិសុខ មានភារកិច្ច ៖

- គ្រប់គ្រងការងារសន្តិសុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ចូលរួមក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសពុករលួយ
- ការពារ ថែរក្សាសណ្តាប់ធ្នាប់នៅក្នុងស្ថាប័នប្រឆាំងអំពើពុករលួយ និងបណ្តាញតាមរាជធានីខេត្ត
- រៀបចំផែនការសន្តិសុខ សណ្តាប់ធ្នាប់របស់អង្គភាពប្រឆាំងអំពើពុករលួយ

- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១៤.-**

ការិយាល័យអនុរក្ស មានភារកិច្ច ៖

- អនុរក្សទីកន្លែងឃាត់ខ្លួន និងទីកន្លែងឃុំខ្លួនបណ្តោះអាសន្នរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ការពារបន្ទប់ស្តាប់ចម្លើយ
- អនុវត្តបែបបទនីតិវិធីប្រគល់-ទទួល ជនដែលបញ្ជូនមក និងបញ្ជូនចេញ
- សហការជាមួយការិយាល័យសន្តិសុខ និងការិយាល័យរដ្ឋបាល ដើម្បីអនុវត្តរបៀបរបបជួបជនដែលត្រូវឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន
- ឃុំគ្រង និងផ្តល់អាហារូបត្ថម្ភដល់ជនដែលត្រូវឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន
- សហការជាមួយការិយាល័យសុខភាព និងកីឡា ដើម្បីពិនិត្យសុខភាពដល់ជនដែលត្រូវឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន
- ការពារសន្តិសុខ និងជូនដំណើរជនសង្ស័យទៅគោលដៅនានាដែលច្បាប់កំណត់
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១៥.-**

ការិយាល័យអន្តរាគមន៍ និងការពារសាក្សី មានភារកិច្ច ៖

- ការពារសុវត្ថិភាពដល់សាក្សី ម្ចាស់បណ្តឹង និងបុគ្គលដែលផ្តល់ព័ត៌មានពាក់ព័ន្ធអំពើពុករលួយ
- ស្នើសុំអន្តរាគមន៍ និងសហការពីសមត្ថកិច្ចកម្លាំងប្រដាប់អាវុធតាមការចាំបាច់ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ជាពិសេសក្នុងភារកិច្ចការពារសាក្សី និងម្ចាស់បណ្តឹង
- សហការជាមួយការិយាល័យសន្តិសុខដើម្បីគាំទ្រដល់ប្រតិបត្តិការបង្ក្រាបបទល្មើសពុករលួយក្នុងករណីចាំបាច់
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១៦.-**

ការិយាល័យសុវត្ថិភាព និងគ្រប់គ្រងអាវុធ មានភារកិច្ច ៖

- គ្រប់គ្រង និងថែទាំសម្ភារៈអាវុធរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់គ្រង ថែរក្សាសម្ភារៈបរិក្ខាផ្សេងៗ សម្រាប់កម្លាំងសន្តិសុខ និងកម្លាំងចុះប្រតិបត្តិការ
- លើកផែនការដាក់កាមេរ៉ាសុវត្ថិភាពក្នុងអង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់គ្រងកាមេរ៉ា (CCTV) របស់អង្គភាពប្រឆាំងអំពើពុករលួយ លើកលែងបន្ទប់ប្រកាសទ្រព្យសម្បត្តិ និងបំណុល
- គ្រប់គ្រងមធ្យោបាយធ្វើដំណើរគ្រប់ប្រភេទ សម្រាប់ចុះប្រតិបត្តិការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

## ជំពូកទី៦
## ការិយាល័យចំណុះនាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល

**ប្រការ ១៧.-**

នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល មានការិយាល័យចំណុះចំនួន៣ ដូចខាងក្រោម ៖

- ការិយាល័យឯកសារ
- ការិយាល័យផែនការ

- ការិយាល័យព័ត៌មាន និងទំនាក់ទំនង ។

**ប្រការ ១៨.-**

ការិយាល័យឯកសារ មានភារកិច្ច ៖

- គ្រប់គ្រងប្រព័ន្ធប្រកាសទ្រព្យសម្បត្តិ និងបំណុល
- រក្សាការសម្ងាត់ចំពោះឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល
- រៀបចំ និងតាក់តែងលិខិតឯកសារគំរូពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ទទួល និងចុះបញ្ជីការលើឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ចូលរួមការបើកស្រោមសំបុត្រ និងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមការសម្រេចរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
- ការពារ និងថែរក្សាឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលឲ្យបានត្រឹមត្រូវ
- គ្រប់គ្រងកាមេរ៉ា(CCTV) បន្ទប់ប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- មន្ត្រីរបស់ការិយាល័យឯកសារ ជាក្រុមជនបង្គោលរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ១៩.-**

ការិយាល័យផែនការ មានភារកិច្ច ៖

- កសាងផែនការសកម្មភាពស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល
- កសាងផែនការស្តីពីកិច្ចសហប្រតិបត្តិការជាមួយក្រុមជនបង្គោលអំពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ធ្វើផែនការសម្រាប់មន្ត្រីរាជការដែលតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ
- ធ្វើផែនការសម្រាប់មន្ត្រីផ្សេងទៀតដែលតែងតាំងដោយប្រកាស ហើយត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមបញ្ជីដែលរៀបចំឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើផែនការសម្រាប់ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ធ្វើផែនការសម្រាប់មន្ត្រីតែងតាំងដោយប្រកាស ក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធនាគារជាតិ និងអង្គភាពស្វយ័តរដ្ឋបាលផ្សេងៗ
- ធ្វើផែនការសម្រាប់ ថ្នាក់ដឹកនាំសង្គមស៊ីវិល ត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ធ្វើផែនការសម្រាប់ ចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និងអាជ្ញាសាលា
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ២០.-**

ការិយាល័យព័ត៌មាន និងទំនាក់ទំនង មានភារកិច្ច ៖

- រៀបចំសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ធ្វើទំនាក់ទំនងជាមួយក្រុមជនបង្គោល និងបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ឆ្លើយបំភ្លឺពាក់ព័ន្ធនឹងការងារប្រកាសទ្រព្យសម្បត្តិ និងបំណុល
- ធ្វើការទំនាក់ទំនងជាមួយ អគ្គលេខាធិការរាជរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធនាគារជាតិ និងអង្គភាពស្វ័យតរដ្ឋបាលផ្សេងៗ ដើម្បីស្នើសុំបញ្ជូនព្រះរាជក្រឹត្យ និងអនុក្រឹត្យឯកត្តភូត
- រៀបចំឲ្យមានប្រព័ន្ធទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មានតាមឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

## ជំពូកទី៧
## ការិយាល័យចំណុះនាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ

**ប្រការ ២១.-**

នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ មានការិយាល័យចំណុះចំនួន៣ ដូចខាងក្រោម ៖

- ការិយាល័យកិច្ចការគតិយុត្ត
- ការិយាល័យពាក្យប្តឹង
- ការិយាល័យអន្តរជាតិ

**ប្រការ ២២.-**

ការិយាល័យកិច្ចការគតិយុត្ត មានភារកិច្ច ៖

- ជំរុញការអនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងអំពើពុករលួយ
- រៀបចំកសាងផែនការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានារបស់អង្គភាពប្រឆាំងអំពើពុករលួយ
- សម្របសម្រួលលើការងារកសាង និងតាក់តែងសេចក្តីព្រាងច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- ចូលរួមពិនិត្យវិភាគពាក្យប្តឹង និងលើកយោបល់លើទិដ្ឋភាពច្បាប់ជូនអង្គភាពប្រឆាំងអំពើពុករលួយ
- រក្សាព័ត៌មានសម្ងាត់ចំពោះអ្នកប្តឹង និងសាក្សី
- សហការជាមួយការិយាល័យផ្សេងៗ ស្ថាប័នមានសមត្ថកិច្ចនានា និងស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ដើម្បីបញ្ជូនសំណុំរឿង និងជនល្មើសទៅតុលាការ
- ទទួលខុសត្រូវក្នុងការរៀបចំ និងពិនិត្យសំណុំរឿងមុននឹងបញ្ជូនទៅតុលាការ
- ចូលរួមធ្វើជាតំណាងអង្គភាពនៅក្នុងនីតិវិធីតុលាការ
- ចូលរួមពិគ្រោះយោបល់ក្នុងដំណើរការស៊ើបអង្កេត
- រៀបចំចម្លើយឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ចំពោះរាល់សំណួរដែលលើកឡើង ដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬសមាជិករដ្ឋសភា
- សម្របសម្រួល និងចាត់ចែងកិច្ចការគតិយុត្តជាមួយមេធាវីរបស់អង្គភាព
- រៀបចំចងក្រងឯកសារច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអំពើពុករលួយ
- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ២៣.-**

ការិយាល័យពាក្យប្តឹង មានភារកិច្ច៖

- ចុះបញ្ជីសំបុត្រ ឬព័ត៌មានដែលទទួលបានតាមគ្រប់ប្រភពជាអាទិ៍ ទូរស័ព្ទ ទូរសារ អ៊ីម៉ែល ប្រៃសណីយ៍ ការិយាល័យទទួលពាក្យប្តឹង និងប្រអប់សំបុត្ររបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ចុះបញ្ជីនូវសំបុត្រ ឬលិខិតណាដែលមានចារឹក និងលក្ខណៈសម្បត្តិជាពាក្យប្តឹង និងធ្វើកំណត់ហេតុ របាយការណ៍ទទួលពាក្យប្តឹង
- ប្រមូលឯកសារក្នុងប្រអប់សំបុត្ររបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើទំនាក់ទំនងជាមួយអ្នកប្តឹង ឬសាក្សីក្នុងការប្រមូលព័ត៌មានបន្ថែម
- គ្រប់គ្រងពាក្យប្តឹងពាក់ព័ន្ធនឹងអំពើពុករលួយគ្រប់ប្រភេទ
- រៀបចំ និងចងក្រងទិន្នន័យនៃពាក្យប្តឹងរបស់អង្គភាពប្រឆាំងអំពើពុករលួយតាមប្រព័ន្ធព័ត៌មានវិទ្យា
- ស្វែងរក ពិនិត្យ និងរៀបចំឯកសារព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ
- រក្សាព័ត៌មានសម្ងាត់ចំពោះអ្នកប្តឹង និងសាក្សី
- រៀបចំធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្តឹង ចំពោះបណ្តឹងដែលមិនពាក់ព័ន្ធនឹងអំពើពុករលួយ

- ធ្វើរបាយការណ៍សកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់អង្គភាព ។

**ប្រការ ២៤.-**

ការិយាល័យអន្តរជាតិ មានភារកិច្ច៖

